២0៣	- Total Coliforms, Plate Count	៨0 000	៣-១0 ថ្ងៃ	
២0៤	- E.Coli, MPN	៧0 000	៣-១0 ថ្ងៃ	
២0៥	- Faecal Coliforms, MPN	៨0 000	៣-១0 ថ្ងៃ	
២0៦	- Listeria monocytogenes	១00 000	៣-១0 ថ្ងៃ	
២0៧	- Salmonmella spp	១២0 000	៣-១0 ថ្ងៃ	
២0៨	- Staphylococcus aureus	១00 000	៣-១0 ថ្ងៃ	
២0៩	- Vibrio Cholerae	១00 000	៣-១0 ថ្ងៃ	
២១0	- E.Coli and Coliform in Water	៨0 000	៣-១0 ថ្ងៃ	
២១១	- Coagulase-Positive Staphylococci	៨0 000	៣-១0 ថ្ងៃ	
២១២	- Yeasts and Molds	៦0 000	៣-១0 ថ្ងៃ	

ជាស ខេមរា ១ ១ ១

លេខរៀងសេវា	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
២១៣	- β-Glucuronidase-positive E.coli	៨០ ០០០	៣-១០ថ្ងៃ	
២១៤	- Enterobacteriaceae	៩០ ០០០	៣-១០ថ្ងៃ	
	៣ សំណាល់សារធាតុពុលគីមីក្នុងម្ហូបអាហារ			
២១៥	- Pesticide Residues in Fresh Fruit and Vegetables by Test Kit	៨០ ០០០	៣-១០ថ្ងៃ	
២១៦	- Pesticide Residues in Fresh Fruit and Vegetables by GC-MS/LC	៣០០ ០០០	៣-១០ថ្ងៃ	
២១៧	- Polycyclic Aromatic Hydrocarbons (PAHs) by Test Kits	៥០ ០០០	៣-១០ថ្ងៃ	
២១៨	- Polycyclic Aromatic Hydrocarbons (PAHs) by GC-MS	៣០០ ០០០	៣-១០ថ្ងៃ	
២១៩	- Polychlorinated Biphenyl (PCBs)	៣០០ ០០០	៣-១០ថ្ងៃ	
២២០	- 3-MCPD in Food by GC-MS	៣០០ ០០០	៣-១០ថ្ងៃ	
២២១	- Micotoxins by HPLC	៣០០ ០០០	៣-១០ថ្ងៃ	
	៤ យថាប្រភេទគុណភាពប្រេងឥន្ធនៈ (Fuel Specifications)			
២២២	- Gasoline	២១០ ០០០	៣-១០ ថ្ងៃ	
២២៣	- Diesel	២៣០ ០០០	៣-១០ ថ្ងៃ	
២២៤	- Kerosene	១៩០ ០០០	៣-១០ ថ្ងៃ	
២២៥	- JET A1	១៩០ ០០០	៣-១០ ថ្ងៃ	
២២៦	- Fuel Oil	១៩០ ០០០	៣-១០ ថ្ងៃ	
២២៧	- Engine Oil	២៥០ ០០០	៣-១០ ថ្ងៃ	
២២៨	- Base Oil	២៥០ ០០០	៣-១០ ថ្ងៃ	

លេខរៀងសេវា	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
២២៩	- Sulfur in Fuel	២០០ ០០០	៣-១០ថ្ងៃ	
២៣០	- Octane Index RON/MON	១៥០ ០០០	៣-១០ថ្ងៃ	
២៣១	- Distillation of Petroleum Products	១៥០ ០០០	៣-១០ថ្ងៃ	
២៣២	- Aromatics in Gasolines	១២០ ០០០	៣-១០ថ្ងៃ	
	៥ ផលិតផលប្រើប្រាស់ (Consumer Products)			
២៣៣	- Asbestos	១២០ ០០០	៣-១០ថ្ងៃ	
២៣៤	- Heavy Metals in Toys by XRF	៦០ ០០០	៣-១០ថ្ងៃ	
២៣៥	- Heavy Metals in Cosmetics by XRF	៦០ ០០០	៣-១០ថ្ងៃ	
២៣៦	- Parabens in Cosmetics by LC	១២០ ០០០	៣-១០ថ្ងៃ	
២៣៧	- Hydroquinone by LC	១២០ ០០០	៣-១០ថ្ងៃ	
	៦ យថាប្រភេទផលិតផលគីមី (Specifications for Chemicals)			
២៣៨	- Test for Purity of Acids	២១០ ០០០	៣-១០ ថ្ងៃ	
២៣៩	- Test for Purity of Organic Solvents	១៦០ ០០០	៣-១០ ថ្ងៃ	
២៤០	- Test for Purity of Salts	១១០ ០០០	៣-១០ ថ្ងៃ	
២៤១	- Test for Purity of Fertilizers	២១០ ០០០	៣-១០ ថ្ងៃ	
២៤២	- Test for Purity of Food Additives	២១០ ០០០	៣-១០ ថ្ងៃ	

ជាភាសាខ្មែរ ១ ១ ១

លេខរៀងសេវា	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
២៤៣	៧ ការវិភាគផ្សេងៗ ដែលមិនមានក្នុងតារាងខាងលើ (Other analysis parameters not specified above)	កំណត់ដោយមន្ទីរពិសោធន៍ ដែលទទួលវិភាគ + ៥០ ០០០	៣-១០ ថ្ងៃ	
	ខ. សេវាយកគំរូផលិតផល ទំនិញនៅតាមបណ្តាខេត្ត-រាជធានី			
២៤៤	- ចម្ងាយផ្លូវយ៉ាងច្រើនត្រឹម ១០០គ.ម	៣០០ ០០០	១ ថ្ងៃ	
២៤៥	- ចម្ងាយផ្លូវលើសពី ១០០គ.ម ទៅ ២០០គ.ម	៣៨០ ០០០	១ ថ្ងៃ	
២៤៦	- ចម្ងាយផ្លូវលើសពី ២០១គ.ម ឡើងទៅ	៥០០ ០០០	១ ថ្ងៃ	
	នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ			
	ក. ត្រួតពិនិត្យជាលក្ខណៈពាណិជ្ជកម្មភាគីទី៣ តាមការស្នើសុំរបស់អតិថិជន			
	១ ការត្រួតពិនិត្យ និងចេញរបាយការណ៍បញ្ជាក់លើបរិមាណ ឬ ទម្ងន់ ក្នុង១ប្រភេទមុខទំនិញ			
២៤៧	- ពីចជាង ១តោន	២០០ ០០០	១-១០ថ្ងៃ	
២៤៨	- ចាប់ពី ១តោន ទៅដល់១០តោន	៤០០ ០០០	១-១០ថ្ងៃ	
២៤៩	- ចាប់ពី ១០តោន ទៅដល់១០០តោន	៨០០ ០០០	១-១០ថ្ងៃ	
២៥០	- ចាប់ពី ១០០តោន	២ ០០០ ០០០	១-១០ថ្ងៃ	
	២ ការត្រួតពិនិត្យបញ្ជាក់អំពីទំនិញខូចគុណភាព			
២៥១	- ត្រួតពិនិត្យ និងចេញរបាយការណ៍បញ្ជាក់ពីស្ថានភាពទំនិញ	៤០០ ០០០	១-១០ថ្ងៃ	
២៥២	- ត្រួតពិនិត្យ និងចេញរបាយការណ៍ [illegible] ទំនិញ ដែលបាក់បែក ឬខូច (Damaged cargoes)	៨០០ ០០០	១-១០ថ្ងៃ	
២៥៣	- ត្រួតពិនិត្យ និងចេញរបាយការណ៍ [illegible] (Spoiled Food)	៤០០ ០០០	១-១០ថ្ងៃ	

លេខរៀងសេវា	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	ខ. សេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូល			
	១ ទំនិញទូទៅ			
	១.១ ទំនិញដឹកជញ្ជូនតាមផ្លូវទឹក			
	+ កុងទែន៉រ :			
២៥៤	- កុងទែន៉រពេញទី១	២៥០ ០០០	១ ថ្ងៃ	
២៥៥	- កុងទែន៉រពេញទី២ និងបន្ទាប់	១៥០ ០០០	១ ថ្ងៃ	
២៥៦	- កុងទែន៉រមិនពេញ	១៥០ ០០០	១ ថ្ងៃ	
	+ ឃ្លីប៉ានាវ :			
២៥៧	- ឃ្លីប៉ាទី១	៤០០ ០០០	១ ថ្ងៃ	
២៥៨	- ឃ្លីប៉ាទី២ និងបន្ទាប់	២០០ ០០០	១ ថ្ងៃ	
២៥៩	- ការងារត្រួតពិនិត្យក្នុង 1shipment	១៦០ ០០០	១ ថ្ងៃ	
	+ ផ្ទុកតាមទូក :			
២៦០	- ទូកមានចំណុះច្រើនជាង ២០តោន	២៥០ ០០០	១ ថ្ងៃ	
២៦១	- ទូកមានចំណុះតិចជាង ឬស្មើ ២០តោន	១៣០ ០០០	១ ថ្ងៃ	
	១.២ ទំនិញដឹកជញ្ជូនតាមផ្លូវគោក			
	+ កុងទែន៉រ :			
២៦២	- កុងទែន៉រពេញទី១	២៥០ ០០០	១ ថ្ងៃ	
២៦៣	- កុងទែន៉រពេញទី២ និងបន្ទាប់	១៥០ ០០០	១ ថ្ងៃ	

លេខរៀងសេវា	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
២៦៤	- ក្នុងទ្រនំរមិនពេញ	១៥0 000	១ ថ្ងៃ	
	+ ផ្ទុកតាមរថយន្ត :			
២៦៥	- ចំណុះលើសពី ១0គោន	១១0 000	១ ថ្ងៃ	
២៦៦	- ចំណុះតិចជាង ឬស្មើ ១0គោន	៩0 000	១ ថ្ងៃ	
	១.៣ ទំនិញដឹកជញ្ជូនតាមយន្តហោះ			
	+ ប៉ាម្ប៉ែត :			
២៦៧	- ប៉ាម្ប៉ែតទី១	១៦0 000	១ ថ្ងៃ	
២៦៨	- ប៉ាម្ប៉ែតទី២ និងបន្តបន្ទាប់	៨0 000	១ ថ្ងៃ	
២៦៩	- ការងារត្រួតពិនិត្យក្នុង១ឯកសារ	៤0 000	១ ថ្ងៃ	
	+ ទំនិញជាកញ្ចប់រាយ :			
២៧0	- បរិមាណច្រើនជាង 0៥កញ្ចប់	៨0 000	១ ថ្ងៃ	
២៧១	- បរិមាណតិចជាង ឬស្មើ 0៥កញ្ចប់	៦0 000	១ ថ្ងៃ	
២៧២	- ការងារត្រួតពិនិត្យក្នុង ១ឯកសារ	៤0 000	១ ថ្ងៃ	
	២ ទំនិញរាវ			
	+ ផ្ទុកក្នុងនាវា :			
២៧៣	- ទំនិញរាវដាក់នៅក្នុងឃ្លាប់ទី១	១៦0 000	១ ថ្ងៃ	
២៧៤	- ទំនិញរាវដាក់នៅក្នុងឃ្លាប់ទី២ និងបន្តបន្ទាប់	៨0 000	១ ថ្ងៃ	
២៧៥	- ការងារត្រួតពិនិត្យក្នុង ១sampling	១៦0 000	១ ថ្ងៃ	

ជាតិ ១០០ ១ ១ ១

លេខរៀងសេវា	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
២៨៨	៦ ទំនិញជាអង្ករ (គិតក្នុង ១shipment)	មិនគិតថ្លៃ	១ ថ្ងៃ	
២៨៩	៧ ទំនិញទូទៅដោះដូរតាមព្រំដែន តាមរបៀង និងមធ្យោបាយសាមញ្ញ	២៥ 000	១ ថ្ងៃ	
២៩0	គ. ការចេញសេចក្តីបញ្ជាក់លើការពិនិត្យសំណុំឯកសារ នាំចូល(គិត ១ ឯកសារ)	៦0 000	១	១ ខែ
	- បញ្ជាក់ទូវកម្រិតហានិភ័យនៃប្រភេទផលិតផលពាក់ព័ន្ធនឹងជើងបញ្ជូនទំនិញ			
	- បង្ហាញប្រព្រឹត្តកម្មជាក់លាក់សម្រាប់ការត្រួតពិនិត្យនៅច្រកចេញ-ចូលម្តងណាមួយ			

ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ.២០២៥..... សហវ.ប្រក ចុះថ្ងៃទី១៣..ខែកក្កដាឆ្នាំ២០២១

ការកំណត់សេវាសាធារណៈ ដែលក្រសួងពាណិជ្ជកម្មធ្វើប្រតិកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្ត

លេខរៀងសេវា	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
១	ការចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃជារូបិយបណ្ណបរទេស	២០០ ០០០	០៥ ថ្ងៃ	១ ឆ្នាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រសួងពាណិជ្ជកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០៤៤ រត.អប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០០៤៤ រត.អប្រក.លអ ..... ចុះថ្ងៃទី ..... ២៧ ..... ខែ ..... មីនា ..... ឆ្នាំ ២០១៩

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ចុះថ្ងៃទី០៦ ខែកញ្ញាឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ស្តីពីការផ្ទេរនិងសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជា ទៅក្រោមក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០១៥របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រកចុះថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០១៧របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០១៥ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរចុះថ្ងៃទី១៦ខែឧសភាឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨ របស់លោក **សុ: វណ្ណនី**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈយីហោ **ដេប៉ូតេលា ម៉ង ស្រីមុំ**ស្ថិតនៅភូមិតំរ៉ែប ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងរបស់លោក **សុ: វណ្ណនី** (ម្ចាស់ស្ថានីយ)។

ប្រការ២.

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារ ដូចខាងក្រោមក្នុងរយៈពេល ១ (មួយ) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. ត្រូវមានលិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរចុះថ្ងៃទី១៦ខែឧសភា ឆ្នាំ២០១៨ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ:ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឲ្យចប់ជាស្ថាពរមុនថ្ងៃទី២៥ខែវិច្ឆិកា ឆ្នាំ២០១៩នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ទីតាំងកបំពង់ទទួលប្រេងឥន្ធនៈ ពីរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ ម៉ែត្រ ឃ្លាតពីអគារការិយាល័យ
២. ពោងប្រេងឥន្ធនៈមួយ ដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៣. ត្រូវបំពាក់គន្លឹះអាសន្នរួម និងគន្លឹះអាសន្នតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ
៤. ទុយោចាក់ប្រេងឥន្ធនៈ ត្រូវមានប្រវែងអតិបរមា ៦ ម៉ែត្រ
៥. មិនត្រូវបំពាក់វ៉ាន បិទ បើកជាប់នឹងតួបំពង់ខ្យល់
៦. គម្របឃ្លុបមាត់ពោង ត្រូវតែជាដែកកាបូន

៧. ទីតាំងទូចាក់ប្រេងឥន្ធនៈ ទៅអគារការិយាល័យ ត្រូវមានចម្ងាយអប្បបរមា ៦ ម៉ែត្រ
៨. ទីតាំងទូចាក់ប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ ឃ្លាតពីព្រំដីស្ថានីយ
៩. ត្រូវមានឧបករណ៍ពន្លត់អគ្គិភ័យ
១០. ត្រូវមានផ្ទាំងព័ត៌មាន និងស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឲ្យបានគ្រប់គ្រាន់
១១. ត្រូវមានគំនូសសញ្ញាសម្រាប់ចំណតរថយន្តផ្ទេរប្រេងឥន្ធនៈ ពីរថយន្តផ្ទេរប្រេងឥន្ធនៈ
១២. ត្រូវមានប្រព័ន្ធញ្ជែកសំណល់ រឹង ប្រេង និងទឹក។

ប្រការ៥.

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែនិងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែនិងថាមពលមុនប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួនប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១នៃត្រីមាសបន្ទាប់និងប្រចាំឆ្នាំនៅសប្តាហ៍ទី១នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឲ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៩.

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាតឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ ០០៤៤ ២៥.អប្ចរ.ស.ហ ចុះថ្ងៃទី ២៧ ខែ ០៦ ឆ្នាំ២០១៩ របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២...

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០០៤.ជ.ផ.ស.ណ.ចុះថ្ងៃទី...២៧.....ខែ.....មីនា.....ឆ្នាំ២០១៩....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣...

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាតអគ្គាធិការប្រធានមន្ទីរអ៊ីនិងថាមពលខេត្តកំពង់ឆ្នាំង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១០រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៩

រដ្ឋមន្ត្រីក្រសួងអ៊ីនិងថាមពល

ស៊ុយ រិសភ

ទីកន្លែងទទួល:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
-សាលាខេត្តកំពង់ឆ្នាំង
-ដូចប្រការ១៣
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០០៣.រធ.អប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃអាជ្ញាបណ្ណមណ្ឌលសន្តិធិរួមប្រេង និងឧស្ម័នឥន្ធនៈ
លេខ.០០០៣.រធ.អប្រក.២២..ចុះថ្ងៃទី..១៩.....ខែ.១សីហា. ឆ្នាំ ២០២០..

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ ១២៨ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញលិខិតស្នើសុំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន កម្ពុជា តេលា
- យោងតាមការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១..

ប្រកាសនេះមានគោលបំណងកំណត់អំពីលក្ខខណ្ឌ ក្នុងការផ្តល់អាជ្ញាបណ្ណមណ្ឌលសន្តិធិសម្រាប់ក្រុមហ៊ុន **កម្ពុជា តេលា** (KAMPUCHEA TELA LIMITED) ដែលបានចុះបញ្ជីពាណិជ្ជកម្មលេខ

០០០១៥៤៦៣ និងមានទីស្នាក់ការនៅអគារលេខ សេ១៦៨ ផ្លូវសហព័ន្ធរុស្សី ភូមិសេប៉ៃ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ "**អ្នកទទួលបានអាជ្ញាបណ្ណ**" ធ្វើការសាងសង់ និងធ្វើប្រតិបត្តិការ និងថែទាំ មណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈ ដែលមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ ភូមិបឹងព្រីង ឃុំបឹងព្រីង ស្រុកថ្មគោល ខេត្តបាត់ដំបង។

ប្រការ២..

អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពធុរកិច្ច ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ (ធុរកិច្ចដែលអនុញ្ញាត)។ ក្នុងករណីអ្នកទទួលបានអាជ្ញាបណ្ណមានបំណងធ្វើធុរកិច្ចផ្សេងទៀត ត្រូវស្នើសុំអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតដោយឡែកសម្រាប់សកម្មភាពដោយឡែក និងត្រូវស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពាក់ព័ន្ធផ្សេងៗ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ៣..

អ្នកទទួលបានអាជ្ញាបណ្ណត្រូវស្នើសុំ និងទទួលបានអាជ្ញាបណ្ណ និង/ឬ លិខិតអនុញ្ញាតផ្សេងៗ ពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ស្របតាមការតម្រូវនៃច្បាប់ជាធរមាន ដើម្បីអនុវត្តកាតព្វកិច្ចនានា ដូចមានចែងក្នុងអាជ្ញាបណ្ណនេះ។

ប្រការ៤ ..

ប្រកាសនេះមានរយៈពេលសុពលភាព ស្របតាមរយៈពេលសុពលភាពនៃអាជ្ញាបណ្ណមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈ លេខ..០០០៣.ន.ធ.អប្រស.២០.. ចុះថ្ងៃទី.១៩.... ខែ.១.ឆ្នាំ.. ឆ្នាំ.២០២០. និងអាចពន្យារបន្តបានស្របតាមអាជ្ញាបណ្ណនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ ៥..

ក្រុមហ៊ុនត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដូចតទៅ៖

១. កាតព្វកិច្ចគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១.១ ក្រុមហ៊ុន ត្រូវធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាពរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការសាងសង់មណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ខ្លួន។ ក្នុងករណីមិនទាន់មានបទដ្ឋានរបស់ក្រសួងរ៉ែ និងថាមពល ក្រុមហ៊ុនត្រូវធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាព តាមឧត្តមានុវត្តជាអន្តរជាតិ ក្នុងការសាងសង់មណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈ។

១.២ ក្រុមហ៊ុន ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងនីតិវិធីនានា ដែលក្រសួងរ៉ែ និងថាមពលសម្រេចដាក់ឱ្យអនុវត្តសម្រាប់កិច្ចដំណើរការសាងសង់ និងធ្វើប្រតិបត្តិការមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈ។

១.៣ ក្រុមហ៊ុន ត្រូវគោរពតាមកាតព្វកិច្ចបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពីការ ការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ របស់ព្រះរាជាណាចក្រកម្ពុជា។

១.៤ ក្រុមហ៊ុន ត្រូវគោរព និងអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននានា របស់ព្រះរាជាណាចក្រកម្ពុជា។

២. កាតព្វកិច្ចក្នុងការរៀបចំមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈ

២.១ ក្រុមហ៊ុនត្រូវធ្វើការរៀបចំមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈនៅលើទីតាំងដែលបានកំណត់។

២.២ ក្រុមហ៊ុន ត្រូវធ្វើការរៀបចំមណ្ឌលមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈ តាមផែនការគំនូសប្លង់ស្ថាបត្យកម្ម និងប្លង់គ្រឿងបង្គុំសំណង់ ដែលមានការយល់ព្រមពីក្រសួងរ៉ែ និងថាមពល។ ក្នុងករណីមានការកែប្រែផែនការ គំនូសប្លង់ផ្សេងៗ ក្រុមហ៊ុនត្រូវស្នើសុំការយល់ព្រមពីក្រសួងរ៉ែ និងថាមពល មុនចាប់ផ្តើមការរៀបចំ។

២.៣ ក្រុមហ៊ុន ត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរៀបចំមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ខ្លួន។

២.៤ ក្រុមហ៊ុន ត្រូវផ្តល់នូវរបាយការណ៍អំពីវឌ្ឍនភាពក្នុងការរៀបចំមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈនេះជាប្រចាំត្រីមាស នៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់។

២.៥ ក្រុមហ៊ុន ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវរាល់ឧបទ្ទវហេតុ និង គ្រោះថ្នាក់ទាំងឡាយ ដែលកើតឡើងក្នុងអំឡុងពេលដំណើរការរៀបចំមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ខ្លួន។

២.៦ ក្រុមហ៊ុន មិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិបង្កើតមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈនេះឱ្យអ្នកដទៃដោយគ្មានការអនុញ្ញាតពីក្រសួងរ៉ែ និងថាមពលឡើយ។

៣. កាតព្វកិច្ចផ្សេងទៀត

៣.១ ក្រុមហ៊ុន ត្រូវផ្តល់ប្លង់បច្ចេកទេសជាក់ស្តែងនៃសំណង់មណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈក្រោយ សាងសង់រួចជាស្ថាពរ មួយច្បាប់ សម្រាប់តម្កល់នៅអគ្គនាយកដ្ឋានប្រេងកាត។

៣.២ ក្រុមហ៊ុន ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យប្រេង និងឧស្ម័នឥន្ធនៈដែលបាននាំចូល និងលក់ចែកចាយជាប្រចាំត្រីមាស នៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំ នៅសប្តាហ៍ទី១នៃឆ្នាំបន្ទាប់ មកក្រសួងរ៉ែនិងថាមពល។

៣.៣ ក្រុមហ៊ុន ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវរាល់ឧបទ្ទវហេតុ និងគ្រោះថ្នាក់ទាំងឡាយ ដែលកើតឡើងក្នុងអំឡុងពេលប្រតិបត្តិការមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ខ្លួន។

៣.៤ ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈមានប្រសិទ្ធភាពខ្ពស់។

ប្រការ៦.

មុនដំណើការមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈនេះរយៈពេល ៩០ (កៅសិប) ថ្ងៃ ក្រុមហ៊ុនត្រូវជូនដំណឹង និងដាក់ពាក្យស្នើសុំ **លិខិតអនុញ្ញាតដំណើរការមណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈ** ពីក្រសួងរ៉ែ និងថាមពល។

ប្រការ៧.

អាជ្ញាបណ្ណនេះ នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌ ប្រសិនបើក្រុមហ៊ុនមិនបានចាប់ផ្តើមសាងសង់មណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈនេះ ក្នុងរយៈពេល១២ (ដប់ពីរ) ខែ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ ឬក្រុមហ៊ុនបានប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រកាសនេះ។

ប្រការ៨.

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តបាត់ដំបង និងប្រធានក្រុមហ៊ុន **កម្ពុជា តេលា** ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចទទួលបន្ទុករៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១៣ កើត ខែ ភ្ជុំ ឆ្នាំ ជូត ១ មស ត.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ១ ២០២០

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ រិសភ

ករណ្ឌទទួល :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-រដ្ឋបាលសាលាខេត្តបាត់ដំបង
-ដូចប្រការ ៨
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០២០១.១៨.អ(ប្រក.)ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតជំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ.០២០១.១៨.អ(ប្រក.ណវ)..ចុះថ្ងៃទី.១៣.....ខែ.កក្កដា.....ឆ្នាំ ២០២០

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញាឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រកចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ខែឧសភាឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់លោក **ទុយ ស៊ីម**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១...

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈយីហោ **លី ណា** ស្ថិតនៅភូមិបួន សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី របស់លោក **ទុយ ស៊ីម** (ម្ចាស់ស្ថានីយ)។

ប្រការ២...

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣...

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភាឆ្នាំ២០១៨ស្តីពីនីតិវិធី នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវបំពេញបន្ថែម នូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤...

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភាឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. កំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ម៉ែត្រពីរបងព្រំដីស្ថានីយ និង៧ម៉ែត្រពីអគារនៅក្នុងស្ថានីយ

២. បំពង់ខ្យល់ត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ម៉ែត្រពីរបងព្រំដីស្ថានីយ

៣. អាងដាក់ពោងកប់ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ១ម៉ែត្រពីគ្រឹះសំណង់ និង២,៥០ម៉ែត្រពីរបងព្រំដីស្ថានីយ
៤. ត្រូវបំពាក់គន្លឹះអាសន្នតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ និងគន្លឹះអាសន្នរួម
៥. ត្រូវមានចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
៦. ត្រូវបំពាក់ស្លាកសញ្ញាបម្រាម និងផ្ទាំងស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
៧. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

ប្រការ៥...

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦...

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧...

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨...

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩...

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០...

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១...

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០២០១.១៨.រជត.លរ.....ចុះថ្ងៃទី..១៣.....ខែ.តុលា.....ឆ្នាំ២០២០.....របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២...

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០២០១.១៨.រជត.លរ.....ចុះថ្ងៃទី.១៣.....ខែ.តុលា.....ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣...

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការប្រធានមន្ទីររ៉ែ និងថាមពលខេត្តរតនគិរី និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ចន្ទ...ត្រង.....ខែ.ភាទ្រ.ឆ្នាំ.ជូ.ឯកស័ក...ព.ស.២៥៦៤.
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.១៣...ខែ.តុលា...ឆ្នាំ២០២០.
រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ុយ.សំអាត

<u>កន្លែងទទួល:</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-សាលាខេត្តរតនគិរី
-ដូចប្រការ១៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០២០ក.រ.ផ.រ.ប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតជំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០២០ក.រ.ផ.រ.ប្រក.លរ...ចុះថ្ងៃទី.១៣.....ខែកក្កដា....ឆ្នាំ ២០២០

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ចុះថ្ងៃទី០៩ ខែធ្នូឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រកចុះថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០១៧របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មីៗ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ របស់លោក **ឆែម ឃាន់**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១...

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ យីហោ **ដេប៉ូតេលា យ៉ែម ឆែម ឃាន់** ស្ថិតនៅភូមិមណ្ឌាយ ឃុំសំព្រោជ ស្រុកស្នោង ខេត្តកំពង់ធំរបស់លោក **ឆែម ឃាន់ (ម្ចាស់ស្ថានីយ)**។

ប្រការ២...

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣...

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្តីពីនីតិវិធី នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវបំពេញបន្ថែម នូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤...

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ត្រូវពង្រីកទំហំក្បាលដីស្ថានីយឱ្យបាន២៥ម៉ែត្រ
២. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយ
៣. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ម៉ែត្រពីព្រំដីស្ថានីយ
៤. បំពង់ខ្យល់ត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ម៉ែត្រពីព្រំដីស្ថានីយ
៥. ទុយោទូចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី៦ម៉ែត្រ
៦. ត្រូវបំពាក់គន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ និងគន្លឹះអាសន្នរួម
៧. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

ប្រការ៥...

ម្ចាស់ស្ថានីយត្រូវគោរព តាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦...

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧...

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

ប្រការ៨...

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៩...

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០...

ម្ចាស់ស្ថានីយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១...

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្នានីយ លេខ.០២០៣.រ៤.អ(ប្រ.ស.ស)ស.....ចុះថ្ងៃទី..១៣.....ខែ..ភក្តិ.....ឆ្នាំ២០២០.....របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២...

ក្នុងករណីស្នានីយនេះ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្នានីយលេខ.០២០៣.រ៤.អ(ប្រ.ស.ស)ស ចុះថ្ងៃទី.១៣.....ខែ.ភក្តិ.....ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣...

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការប្រធានមន្ទីររ៉ែនិងថាមពលខេត្តកំពង់ធំ និងម្ចាស់ស្នានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ជ.....ផ.....ខែ.....ឆ្នាំ.....ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣.....ខែ.ភក្តិ.....ឆ្នាំ២០២០.

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ីយ.រ៉ែសម

<u>កន្លែងទទួល:</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-សាលាខេត្តកំពង់ធំ
-ជូចប្រការ១៣
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០២០៤.រ.ស.ប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ.០២០៤.រ.ស.ប្រក.លអ..ចុះថ្ងៃទី.១៣.....ខែ.តុលា.....ឆ្នាំ ២០២០

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ ១២៨សហវ.ប្រកចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ:ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ របស់លោកស្រី **គឹម រ៉ានី**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១...

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈយីហោ **ដេប៉ូតេលា រីយ៉ា រ៉ាយុទ្ធ** ស្ថិតនៅភូមិក្រាំងស្ពួល ឃុំឦ្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ របស់លោកស្រី **គឹម រ៉ានី (ម្ចាស់ស្ថានីយ)**។

ប្រការ២...

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣...

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្តីពីនីតិវិធី នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយ ត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤...

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. គំនូសប្លង់របស់ស្ថានីយត្រូវមានភាពសមស្របតាមទីតាំងជាក់ស្តែងរបស់ស្ថានីយនិងត្រូវស្របតាមសារាចររបស់ក្រសួងរ៉ែ និងថាមពល
២. មិនអនុញ្ញាតឱ្យមានបន្ទប់ស្នាក់នៅក្នុងបរិវេណស្ថានីយ
៣. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៤. ត្រូវបំពាក់គន្លឹះអាសន្នរួម
៥. កបំពង់ទទួលប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ម៉ែត្រពីរបងព្រំដីស្ថានីយ និងបំពង់ខ្យល់ត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ម៉ែត្រពីរបងព្រំដីស្ថានីយ
៦. មិនត្រូវបំពាក់វ៉ានបិទ-បើកនៅជាប់នឹងតួបំពង់ខ្យល់
៧. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
៨. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់។

ប្រការ៥...

ម្ចាស់ស្ថានីយត្រូវគោរព តាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦...

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧...

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

ប្រការ៨...

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៩...

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០...

ម្ចាស់ស្ថានីយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១...

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០២០៤.១៨.រ៉ូ.ល២.....ចុះថ្ងៃទី.១៣.....ខែ.តុលា.....ឆ្នាំ២០២០.....របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២...

ក្នុងករណីស្ថានីយនេះ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០២០៤.១៨.រ៉ូ.ល២ ចុះថ្ងៃទី.១៣.....ខែ.តុលា.....ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣...

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តកំពង់ស្ពឺ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ៤ រោچ ១០ រោچ ខែ ភាទ្រ ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.១៣.....ខែ.តុលា.....ឆ្នាំ២០២០.

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ីម រ៉ាស្មី

<u>កន្លែងទទួល:</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-សាលាខេត្តកំពង់ស្ពឺ
-ដូចប្រការ១៣
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០២០៤.១៤.អ(ឃក.ឃក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០២០៤.១៤.អ(ឃក.លអ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០២០

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ ១២៨សហវ.ប្រកចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោកស្រី **មុជ លក្ខិណា**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១...

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈយីហោ **TOTAL ទួលទំពូង** ស្ថិតនៅផ្លូវលេខ៤៣០ កែងនឹងផ្លូវលេខ៤៣២ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ របស់លោកស្រី **មុជ លក្ខិណា (ម្ចាស់ស្ថានីយ)**។

ប្រការ២...

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣...

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្តីពីនីតិវិធី នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី

២. លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤...

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ទូចាក់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ម៉ែត្រ ពីព្រំដីស្ថានីយ
២. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ម៉ែត្រពីព្រំដីស្ថានីយ
៣. បំពង់ខ្យល់ត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ម៉ែត្រពីព្រំដីស្ថានីយ
៤. អាងពោងប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ម៉ែត្រពីលំនៅដ្ឋាន។

ប្រការ៥...

ម្ចាស់ស្ថានីយត្រូវគោរព តាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦...

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧...

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

ប្រការ៨...

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៩...

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០...

ម្ចាស់ស្ថានីយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១...

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្នានីយ លេខ០២០៤.១៨.ផ.ប្រភ.លអ.....ចុះថ្ងៃទី..១៣.....ខែ.កក្កដា.....ឆ្នាំ២០២០.....របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២...

ក្នុងករណីស្នានីយនេះ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្នានីយលេខ០២០៤.១៨.ផ.ប្រភ.លអ ចុះថ្ងៃទី.១៣.....ខែ.កក្កដា.....ឆ្នាំ២០២០...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣...

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានីភ្នំពេញ និងម្ចាស់ស្នានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ....៥រោច....ខែមាឃ....ឆ្នាំជូត ទោស័ក....ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣.....ខែ.កក្កដា.....ឆ្នាំ២០២០.

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ុយ រិទ្ធ

<u>កន្លែងទទួល:</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-សាលារាជធានីភ្នំពេញ
-ដូចប្រការ១៣
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី